ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់គ្នា

រវាង

## អង្គការការីតាស ស្វីស

និង

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## ស្តីពី

## ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទម្រង់ផ្សេងទៀតនៃការ
## កេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក

២០២២ - ២០២៤

# សង្ខេបគម្រោង

| | |
|---|---|
| ឈ្មោះអង្គការ: | ការីតាស ស្វីស |
| ប្រភេទអង្គការ: | អង្គការអន្តរជាតិ មិនមែនរដ្ឋាភិបាល |
| អាសយដ្ឋាន: | បន្ទប់B0២ ផ្ទះ៥៦ ផ្លូវ៣០៦ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| លេខទូរស័ព្ទទំនាក់ទំនង: | (៨៥៥) ១២៩៨៥៧៩៦ |
| អ៊ីម៉ែល: | cambodia@caritas.ch |
| ឈ្មោះគម្រោងសកម្មភាព: | ចំណាកស្រុកដោយសុវត្ថិភាពនៅកម្ពុជា |
| លេខកូដគម្រោង: | P_២២០00១ ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងរាល់ទម្រង់បំពាបំពាននានាក្នុងការធ្វើចំណាកស្រុកតាមរយៈការទប់ស្កាត់ ការការពារ និងផ្តល់សេវាសមាហរណកម្ម ព្រមទាំងបង្កើនការសម្របសម្រួលរវាងដៃគូពាក់ព័ន្ធ |
| ទីតាំងគម្រោង: | ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ស្រុកកំរៀង និងខេត្តបាត់ដំបង |
| ដៃគូអនុវត្តគម្រោង: | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដំណាក់ទឹក |
| ថវិកាអនុវត្តគម្រោង: | ២,១៥២,៣៨៨ ស្វីសហ្វ្រង់ |
| កាលបរិច្ឆេទចាប់ផ្តើម: | ថ្ងៃទី០១ ខែមករា ឆ្នាំ ២០២២ |
| កាលបរិច្ឆេទបញ្ចប់: | ថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៤ |
| ចំនួនបុគ្គលិកខ្មែរ: | ២៥នាក់ (ស្រី ១១នាក់) |
| ចំនួនបុគ្គលិកបរទេស: | ០២នាក់ |
| អ្នកគ្រប់គ្រងគម្រោង: | លោកស្រី ឆាយ ឈុនលី |

# អនុស្សរណៈនៃការយោគយល់គ្នា

## រវាង

# អង្គការការីតាស ស្វីស

## និង

# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## ស្ដីពី

# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក

## ផ្នែកទី១
## បុព្វកថា

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អង្គការការីតាស ស្វីស ត្រូវសហការគ្នាក្នុងការបង្ការទប់ស្កាត់ ការការពារ និងការធ្វើសមាហរណកម្ម ចំណាកស្រុក និងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តាមរយៈកិច្ចព្រមព្រៀងក្នុងភាពជាដៃគូដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នា។

**ដោយហេតុថា៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អង្គការការីតាស ស្វីស បានយល់ព្រមសហការដូចមានចែងសកម្មភាពជាក់ស្ដែងដូចខាងក្រោម៖

**១) គោលដៅគម្រោង៖**

រួមចំណែកកាត់បន្ថយការជួញដូរមនុស្ស និងលើកស្ទួយការធ្វើចំណាកស្រុកដោយសុវត្ថិភាពតាមរយៈការទប់ស្កាត់ ការការពារ ការធ្វើសមាហរណកម្ម និងការសម្របសម្រួលភាគីពាក់ពន្ធ័ ។

## ២) គម្រោងសកម្មភាព៖

គម្រោងចំណាកស្រុកដោយសុវត្ថិភាពគឺជាការរួមបញ្ចូលគ្នានៃគម្រោងពីរដែលទទួលបានជោគជ័យកន្លងមកគឺគម្រោង "ការទប់ស្កាត់អំពើជួញដូរមនុស្ស និងមណ្ឌលបណ្តុះបណ្តាលជំនាញសម្រាប់ស្ត្រីងាយរងគ្រោះ" និងគម្រោង "ការការពារ និងសិទ្ធកុមារនៅកម្ពុជា" រួមទាំងគម្រោងសាកល្បង "មណ្ឌលទទួលពលករកំរៀង" ដោយបង្កើនបទពិសោធន៍ និងពង្រឹងបន្ថែមនូវនិរន្តរភាពនៃគម្រោងស្របពេលដែលអនុវត្តសកម្មភាពថ្មីៗដើម្បីបំពេញបន្ថែមលើសកម្មភាពបច្ចុប្បន្ន ឆ្ពោះទៅរកការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការគាំទ្រពលករចំណាកស្រុកឲ្យកាន់តែទូលំទូលាយ ជាពិសេសស្ត្រី និងកុមារ។

គម្រោងនេះមានដៃគូអនុវត្តចំនួនបីនឹងសហការគ្នាទៅវិញទៅមកទាំងវិធីសាស្ត្រក៏ដូចជាទីតាំងភូមិសាស្ត្រផងដែរ។

**អង្គការដំណក់ទឹក** ៖ ការីតាស និងបន្តភាពជាដៃគូដ៏រឹងមាំ និងប្រកបដោយផ្លែផ្កាជាមួយអង្គការដំណក់ទឹក ធ្វើការជាមួយកុមារងាយរងគ្រោះនៅក្រុងប៉ោយប៉ែត។ ភាពជាដៃគូនេះស្ថិតនៅក្នុងសមាសភាគទី១នៃគម្រោង។

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** ការីតាស នឹងរួមបញ្ចូលព្រមទាំងពង្រឹងភាពជាដៃគូជាមួយ គ.ជ.ប.ជ ដែលធ្វើការជាមួយពលករចំណាកស្រុកនៅស្រុកកំរៀង ខេត្តបាត់ដំបង។ ភាពជាដៃគូនេះស្ថិតនៅក្នុងសមាសភាគទី២នៃគម្រោង។

**ការីតាសស្វីស៖** ការគាំទ្រនូវយុទ្ធសាស្ត្រនៃការគ្រប់គ្រងដែលស្ថិតនូវសមាសភាគទី៣នៃគម្រោង។

## ៣) គោលបំណងជាក់លាក់គម្រោង៖

ដើម្បីបង្កើតបរិយាកាសសុវត្ថិភាពសម្រាប់កុមារដែលងាយរងគ្រោះ យុវជន និងស្ត្រីនៅក្នុងតំបន់គោលដៅតាមរយៈវិធានការទប់ស្កាត់ និងការឆ្លើយតបទាន់ពេលទៅនឹងតម្រូវការរបស់ជនរងគ្រោះដោយការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភបំពាន។

## ៤) លទ្ធផលគម្រោង៖

១. **ការទប់ស្កាត់** ៖ លទ្ធផលដែលទាក់ទងនឹងការទប់ស្កាត់ គម្រោងនឹងធ្វើការលើកកម្ពស់ការយល់ដឹងអំពីការធ្វើចំណាកស្រុកតាមរយៈវិធានការនានានៅតាមសហគមន៍។ គោលបំណងនៃគម្រោងគឺដើម្បីចូលរួមចំណែកយ៉ាងធំជាមួយភាគីពាក់ព័ន្ធ ពោលគឺស្ថាប័ន និងប្រជាជននៅសហគមន៍ (អ្នកដឹកនាំសហគមន៍ សេវាសង្គម កុមារ និងឪពុកម្តាយរបស់ពួកគេ អ្នកស្ម័គ្រចិត្ត) និងលើកកម្ពស់ការយល់ដឹង

អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព សុខុមាលភាពកុមារ និងសិទ្ធិ។ ក្រុមគោលដៅចំនួន 6000 នាក់នឹងទទួលបានសេវារៀងរាល់ឆ្នាំ។

២. **ការការពារ ៖** ក្រុមគោលដៅដែលនឹងទទួលបានសេវាការពារ ជាពិសេសកុមារ និងស្ត្រី នឹងទទួលបានសេវាជំនួយបន្ទាន់ និងសេវាមូលដ្ឋានដូចជា ទីជម្រក អាហារ និងជំនួយផ្លូវចិត្ត។ ក្រុមគោលដៅចំនួន ១០០ នាក់នឹងទទួលបានសេវានេះរៀងរាល់ឆ្នាំ។

៣. **ការធ្វើសមាហរណកម្ម ៖** ដើម្បីផ្តល់សេវាសមាហរណកម្មចំពោះជនរងគ្រោះកុមារ យុវជន និងស្ត្រីវ័យក្មេងទៅគ្រួសារ សហគមន៍ និងសង្គម តាមរយៈការអប់រំ ការរកប្រាក់ចំណូល និងការផ្តល់ជំនាញការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវារកការងារធ្វើ។ ក្រុមគោលដៅមានចំនួន ២១៣០នាក់នឹងទទួលបានសេវានេះរៀងរាល់ឆ្នាំ ។

៤. **ការសម្របសម្រួល៖** ការីតាសនឹងផ្តល់ការគាំទ្រដល់ដៃគូអនុវត្តទាំងផ្នែកបច្ចេកទេស និងរដ្ឋបាលក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួលជាមួយមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ និងរចនាសម្ព័ន្ធសហគមន៍ដើម្បីគាំទ្រលទ្ធផលទាំងបីខាងលើ ។

## ផ្នែកទី២

## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**ប្រការ១៖** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គាំទ្របេសកកម្ម អង្គការការីតាស ស្វីស និងអង្គការដៃគូបំពេញការងាររបស់ខ្លួនដោយអនុវត្តស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២៖** សម្របសម្រួលជាមួយ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្តថ្នាក់ក្រោមជាតិ ដើម្បីចូលរួមសហការសកម្មភាពនានារបស់អង្គការការីតាស ស្វីស និងអង្គការដៃគូ ដើម្បីសម្រេចលទ្ធផលដូចមានចែងខាងលើ។

**ប្រការ៣៖** បង្កើតមណ្ឌលទទួលពលករកំរៀងដែលមានពហុមុខងារ ជាមណ្ឌលគំរូសម្រាប់ការបង្កើតមណ្ឌលនៅទីតាំងផ្សេងទៀត។

**ប្រការ៤៖** ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ខេត្តដូចជា៖ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តប៉ៃលិន សៀមរាប និងឧត្តមានជ័យដើម្បីសម្របសម្រួលអ្នកពាក់ព័ន្ធក្នុងការដោះស្រាយការចំណាកស្រុកដោយប្រថុយប្រថាននិងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

**ប្រការ៥៖** ចែករំលែកព័ត៌មាន និងបទពិសោធន៍ល្អ និងលទ្ធផលសម្រេចបាននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជាផលប្រយោជន៍នៃការទំនាក់ទំនងនិងលើកស្ទួយប្រសិទ្ធភាពការងារក្នុងការទប់ស្កាត់ ការការពារ និងសមាហរណកម្មអ្នកចំណាកស្រុកដែលងាយរងគ្រោះ និងកុមារដែលត្រូវបានគេជួញដូរ។

## ផ្នែកទី៣

## ការទទួលខុសត្រូវរបស់អង្គការការីតាស ស្វីស

**ប្រការ៦៖** អង្គការការីតាស ស្វីស នឹងគ្រប់គ្រងថវិកាកម្មវិធី សម្រាប់ការអនុវត្តសកម្មភាពរបស់គម្រោងឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលចំគោលដៅ និងត្រូវគោរពឲ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទបញ្ញត្តិទាំងឡាយ របស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឲ្យបុគ្គលិក និងអង្គការដៃគូរបស់ខ្លួនចូលរួមនូវរាល់សកម្មភាពទាំងឡាយណាដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀត ដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា ។

**ប្រការ៧៖** អង្គការការីតាស ស្វីស នឹងទទួលខុសត្រូវក្នុងការគ្រប់គ្រងគម្រោង គាំទ្រដល់ការការពារទេសន្តប្រវេសន៍ការងារដល់អ្នកងាយរងគ្រោះដោយចំណាកស្រុក និងកុមារប្រឈមនឹងការជួញដូរមនុស្ស ស្របតាមផែនការសកម្មភាព និងគោលនយោបាយរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគោលការណ៍ នៃកិច្ចសហប្រតិបត្តិការដែលមានចែងនៅក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះ។

**ប្រការ៨៖** អង្គការការីតាស ស្វីស នឹងពង្រឹងភាពជាដៃគូរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នូវរាល់សកម្មភាព និងផ្តល់ព័ត៌មានដល់ក្រុមគោលដៅ។ ការផ្លាស់ប្តូរព័ត៌មានពីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាក់ទងនឹងការជួញដូរមនុស្ស និងការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងផ្តល់របាយការណ៍ស្តង់ដាប្រចាំឆ្នាំតាមទម្រង់របាយការណ៍របស់រដ្ឋាភិបាលទៅកាន់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ប្រការ៩៖** អង្គការការីតាស ស្វីស គួរតែផ្តោតលើសកម្មភាពទាក់ទងនឹងការចំណាកស្រុកប្រកបដោយសុវត្ថិភាព និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ត្រូវចៀសវាងរាល់សកម្មភាពទាក់ទងនឹងនយោបាយ ប្រាក់ចំណូល និងចំណេញពីសកម្មភាពការងារចំណាកស្រុក ។

**ប្រការ១០៖** អង្គការការីតាស ស្វីស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន អ្នកតំណាង និងនាយកគម្រោងដែលបានចាត់តាំង ។

## ផ្នែកទី៤

## អវសានប្បញ្ញត្ត

**ប្រការ១១៖** ភាគីទាំងពីរយល់ព្រមចាត់តាំងជនបង្គោលដើម្បីទំនាក់ទំនង និងអនុវត្តការងារ នៃអនុស្សរណៈនេះ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងចាត់តាំងលោក លោកស្រី វ៉ន សុភ័ក្ត្របញ្ញា តួនាទី [illegible] ទូរស័ព្ទទំនាក់ទំនង ០៨៥៥៨៥១៥៧ និងអ៊ីមែល pagna.kh@ncct.gov.kh និងអង្គការការីតាស ស្វីស នឹងចាត់តាំងលោក ខាំ ស៊ីងួន អ្នកគ្រប់គ្រងកម្មវិធី ទូរស័ព្ទលេខ ៨៥៥១២៩៨៥៧៩៦និងអ៊ីម៉ែល syngoun@caritas.ch។

**ប្រការ១២៖** រាល់វិវាទរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការការីតា ស្វីស ទាក់ទងទៅនឹងការអនុវត្ត ឬការបកស្រាយអនុស្សរណៈនេះ នឹងត្រូវបានដោះស្រាយតាមរយៈការចរចារដោយសន្តិវិធីរវាងភាគីទាំងពីរ។

**ប្រការ១៣៖** អនុស្សរណៈនៃការយោគយល់គ្នានេះ អាចបញ្ចប់ដោយភាគីណាមួយក៏បាន គឺបន្ទាប់ពី៦០ថ្ងៃ ដែលភាគីនោះផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជូនទៅភាគីម្ខាងទៀត ។

**ប្រការ១៤៖** អនុស្សរណៈនេះចូលជាធរមាននៅពេលដែលភាគីទាំងពីរចុះហត្ថលេខា និងមានសុពលភាពរយៈពេល៣ឆ្នាំ ហើយនឹងត្រូវបន្តសុពលភាពដោយមានការយល់ព្រមពីភាគីទាំងពីរ។

**ប្រការ១៥៖** អនុស្សរណៈនេះធ្វើឡើងជាពីរច្បាប់ដើម ជាភាសាខ្មែរ និងភាសាអង់គ្លេស ដោយអត្ថបទទាំងពីរមានតម្លៃស្មើគ្នា។

ថ្ងៃ សុក្រ ៤រោច ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២២

តំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

អនុប្រធានអចិន្ត្រៃយ៍

**ជូ ប៊ុនអេង**

តំណាងអង្គការការីតាស ស្វីស

នាយកប្រចាំប្រទេស

**ម៉ាក ភួគល័រ**

ប្រធានកម្មវិធី

**ខាំ ស៊ីខួន**